**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **ខ្មែរ**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jul-2015, 13:24
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# សេចក្តីបញ្ជាក់របស់មេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងឯកសារពីរ ជាភាសាអាល្លឺម៉ង់

---

ដាក់ដោយ៖

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តារា

ចៅក្រម Claudia FENZ

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Clément BOSSIS

កញ្ញា អ៊ុច ស្រីផាត់

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្តីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ មេធាវីការពារក្តីលោក ខៀវ សំផន (“មេធាវីការពារក្តី”) បាន ដាក់បញ្ជីឯកសារដែលស្នើឡើង សម្រាប់សំណុំរឿង ០០២/០២[1]។

២. នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានចេញសេចក្តីសម្រេចស្តីពីការទទួលយកយកឯកសារដែលស្នើឡើងដោយភាគី[2] ដោយបានបញ្ជាក់ថា៖ *“ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃថា តើឯកសារដ៏វែងចំនួនបី ជាភាសាអាល្លឺម៉ង់ ដែលបានដាក់ដោយមេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន ជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ឬយ៉ាងណា និងដើម្បីជៀសវាងការដាក់បន្ទុកដល់អង្គភាពបកប្រែភាសា ក្នុងការបកប្រែសំណើសុំដែលមិនមានសារប្រយោជន៍នោះ មេធាវីការពារក្តីត្រូវបានស្នើឲ្យបញ្ជាក់ថាផ្នែកណាខ្លះនៃឯកសារទាំងនេះ ដែលខ្លួនស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ការបញ្ជាក់នេះគួរបញ្ចូលនូវចំណុចដែលសមស្រប រួមមាន សេចក្តីបរិយាយពិស្តារនៃលក្ខណៈ និងខ្លឹមសារនៃឯកសារទាំងនេះ រួមទាំងការលើកឡើងអំពីចំណុចដែលជាប់ពាក់ព័ន្ធនានាទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការបញ្ជាក់នេះគួរត្រូវបានដាក់ក្នុងរយៈពេល ១៤ ថ្ងៃ បន្ទាប់ពីចេញសេចក្តីសម្រេចនេះ”*[3]។

៣. ក្នុងចំណោមឯកសារទាំងបីដែលអង្គជំនុំជម្រះបានលើកឡើង ឯកសារពីរត្រូវបានស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន គឺឯកសារ D359/1/1.1.28 និងឯកសារ D359/1/1.1.53[4]។

៤. តាមរយៈសារណានេះ សូមអង្គជំនុំជម្រះមេត្តាកត់សម្គាល់ថា មេធាវីការពារក្តីបានផ្តល់សេចក្តីចង្អុលបង្ហាញគ្រប់គ្រាន់ តាមការស្នើសុំរួចមកហើយ ពាក់ព័ន្ធនឹងឯកសារទាំងពីរនេះ នៅពេលដាក់

---

[1] ឯកសារស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ **E305/12** រួមនឹងឧបសម្ព័ន្ធចំនួន ៤៖ **E305/12.2**, **E305/12.3**, **E305/12.4** និង **E305/12.5**។

[2] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារទាំងឡាយដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E305/17**។

[3] ដូចយោងខាងលើ កថាខណ្ឌ ២៩។

[4] ដូចយោងខាងលើ កថាខណ្ឌ ២៩ កំណត់សម្គាល់ជើងទំព័រ ៥៩។

បញ្ជីឯកសារ កាលពីមួយឆ្នាំមុន[5]។ ដូច្នេះ សូមអង្គជំនុំជម្រះពិនិត្យមើលបញ្ជីឯកសារនោះ។

៥. ប៉ុន្តែ មេធាវីការពារក្តីសូមបញ្ជាក់ថា ចំពោះឯកសារ D359/1/1.1.28 ទំព័រពាក់ព័ន្ធដែលបានផ្តល់ជូនពីលើកមុន (ERN 00537031) គឺខុសទេ តាមពិតទៅ គឺទំព័របន្ទាប់ (ERN 00537032)។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |

[5] ឧបសម្ព័ន្ធ **E305/12.2** ទំព័រ ៤ (ERN KH 00994118) និងទំព័រ ១០ (ERN KH 00994124)។